សេចក្តីប្រកាសសារព័ត៌មាន

# យុវជនកម្ពុជាប្តេជ្ញាចិត្តគាំទ្រការអភិរក្សសត្វខ្លាធំ

**ថ្ងៃទី២៩ កក្កដា ឆ្នាំ២០២២** — តំណាងយុវជនកម្ពុជា២រូបបានចូលរួមក្នុងកិច្ចប្រជុំកំពូលយុវជនសត្វខ្លាធំអន្តរជាតិ ដែលបានរៀបចំឡើងដោយអង្គការ WWFឥណ្ឌា និង កម្មវិធីអភិរក្សសត្វខ្លាធំនៃអង្គការWWFថ្នាក់តំបន់ កាលពីថ្ងៃទី២៨ កក្កដា ឆ្នាំ២០២២ និងបានបង្ហាញការប្តេជ្ញាចិត្តរបស់ពួកគេក្នុងការអភិរក្សសត្វខ្លា និងសត្វព្រៃក្នុងដែនជម្រកធម្មជាតិនៃប្រទេសកម្ពុជា។

**កញ្ញា ឡុង សាពណ៌** យុវជនសុច្ឆន:តំណាងប្រទេសកម្ពុជាមួយរូប ដែលចូលរួមក្នុងកិច្ចប្រជុំកំពូលយុវជននាពេលនេះ យល់ថានេះជាការចាំបាច់ក្នុងការចូលរួមរបស់យុវជនកម្ពុជាជាមួយនឹងយុវជនដទៃទៀតក្នុងពិភពលោក ដើម្បីអំពាវនាវឲ្យមានការគាំទ្រ និងការចូលរួមកាន់តែច្រើនថែមទៀតក្នុងការអភិរក្សសត្វខ្លាធំ និងសត្វព្រៃដទៃទៀតសម្រាប់ជាប្រយោជន៍ដល់ធម្មជាតិ និងមនុស្ស។ យុវតីវ័យ១៩ឆ្នាំរូបនេះលើកឡើងថា៖ «យើងមិនខ្វះខ្វាយពេលវេលារង់ចាំបន្តទៀតទេ ពេលនេះហើយជាពេលដែលយុវជនកម្ពុជាប្រមូលផ្តុំកម្លាំងគ្នាក្នុងការគាំទ្រការអភិរក្ស រួមនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការWWF និងដៃគូពាក់ព័ន្ធនានាក្នុងការការពារសត្វព្រៃ។»

កិច្ចប្រជុំកំពូលយុវជនដែលលើកនេះរៀបចំពីចម្ងាយ ត្រូវបានប្រារព្ធធ្វើឡើងរៀងរាល់១២ឆ្នាំម្តងត្រូវនឹងឆ្នាំសត្វខ្លាតាមប្រតិទិនចន្ទគតិ ដោយមានការចូលរួមយុវជនមកពីប្រទេសចំនួន១៣ប្រទេសដែលជាទីជម្រកសត្វខ្លាធំ ក្នុងនោះរួមមានប្រទេសកម្ពុជាផងដែរ ដើម្បីអំពាវនាវឲ្យមានកិច្ចខិតខំកាន់តែខ្លាំងថែមទៀតក្នុងការការពារសត្វខ្លាធំ។

យុវជនសុច្ឆន:តំណាងប្រទេសកម្ពុជាមួយរូបទៀត **លោក ម៉ាន ហ្វាយ៉ានីន** បានរៀបរាប់ថាថ្វីបើសត្វខ្លាធំបានផុតពូជពីព្រៃធម្មជាតិនៃប្រទេសកម្ពុជាមែន ប៉ុន្តែសត្វនេះនៅតែមានសារ:សំខាន់សម្រាប់រូបគេ និងប្រព័ន្ធអេកូឡូស៊ី។ យ៉ានីនលើកឡើងថា៖ «ខ្ញុំបានឮតាមចាស់ៗជំនាន់មុនថាកាលពីដើមឡើយមានសត្វខ្លាធំនៅព្រៃធម្មជាតិយើង ខ្ញុំនៅតែមានការជឿជាក់ថានៅពេលដែលយើងធ្វើការរួមគ្នាកាន់តែខ្លាំងក្លា សត្វខ្លាធំនឹងមានវត្តមានឡើងវិញនៅក្នុងព្រៃរបស់កម្ពុជានាពេលអនាគត។ យុវជននៅជំនាន់ខ្ញុំនេះ សង្ឃឹមនិងប្តេជ្ញាយ៉ាងមុតមាំចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងនេះអោយទទួលបានជោគជ័យ។»

បច្ចុប្បន្នយុវជនកម្ពុជាកំពុងតែមានភាពក្លៀវក្លាចូលរួមក្នុងការអភិរក្សសត្វព្រៃក្នុងប្រទេសកម្ពុជា ក៏ដូចជាពិភពលោកទាំងមូល ស្របពេលដែលស្ថានភាពបរិស្ថានពិភពលោកកំពុងជួបប្រទះបញ្ហាប្រឈមយ៉ាងស្មុគស្មាញ។

**លោក សេខ ឡៀក** នាយកអង្គការWWF បានមានប្រសាសន៍ថា៖ «ខ្ញុំសូមសាទរដល់ការចូលរួមរបស់យុវជនកម្ពុជាក្នុងកិច្ចប្រជុំកំពូលយុវជនខ្លាធំអន្តរជាតិ ជាទីដែលពួកគេបានផ្ញើរសាររួមគ្នាជាមួយយុវជនដទៃទៀតនៅក្នុងប្រទេសដែលជាទីជម្រកសត្វខ្លាធំ ក្នុងការអំពាវនាវដល់រដ្ឋាភិបាល

និងដៃគូពាក់ព័ន្ធទាំងអស់ក្នុងការរួបរួមគ្នាដើម្បីអភិរក្សសត្វខ្លាធំ។» លោកបន្តថា៖ «ការលើកទឹកចិត្តឲ្យមានការចូលរួមពីសំណាក់យុវជនក្នុងការអប់រំបរិស្ថាន និងជួយពួកគេអោយមានទំនាក់ទំនងល្អជាមួយធម្មជាតិ គឺមានសារៈសំខាន់ណាស់ក្នុងការធានាអនាគតមួយដែលមាននិរន្តរភាព។»

លោក Stuart Chapman ប្រធានកម្មវិធីអភិរក្សសត្វខ្លាធំនៃអង្គការWWFថ្នាក់តំបន់ បានមានប្រសាសន៍ថា៖ «សំឡេងរបស់យុវជនចាំបាច់ត្រូវបានលឺដោយអ្នកធ្វើសេចក្តីសម្រេចចិត្តនៅក្នុងប្រទេសដែលជាទីជម្រកសត្វខ្លាធំ ដើម្បីធានាថាយើងអាចបង្កើតអនាគតមួយ ដែលសត្វខ្លាធំ ក្លាយជាកេរដំណែលអភិរក្សសម្រាប់មនុស្សជំនាន់ក្រោយ។»

នៅកម្ពុជា សត្វខ្លាធំចុងក្រោយត្រូវបានថតជាប់ដោយម៉ាស៊ីនថតស្វ័យប្រវត្តិ កាលពីឆ្នាំ២០០៧ នៅដែនជម្រកសត្វព្រៃស្រែពក ក្នុងខេត្តមណ្ឌលគិរី។ ក្នុងឆ្នាំ២០១៦ អ្នកវិទ្យាសាស្ត្របានប្រកាសថាសត្វខ្លាធំត្រូវបានផុតពូជពីព្រៃធម្មជាតិនៃកម្ពុជា។

ការស្តារសត្វខ្លាធំឡើងវិញនៅកម្ពុជា នៅតែជាគោលដៅអភិរក្សរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការWWF ក៏ដូចជាដៃគូពាក់ព័ន្ធ។ កិច្ចការងារនេះរួមបញ្ចូលទាំង ការស្តារប្រភេទសត្វដែលជាចំណីរបស់សត្វខ្លាធំ(សត្វរំពារ) ការរៀបចំឲ្យមានលក្ខខណ្ឌអេកូឡូស៊ីនិងទីជម្រកសមស្របដើម្បីគាំទ្រការអនុវត្តផែនការស្តារសត្វខ្លាធំនាពេលអនាគត។ តំបន់ព្រៃទេសភាពខ្ពង់រាបភាគខាងកើតនៅតែជាតំបន់ព្រៃធម្មជាតិដែលមានសារៈសំខាន់ជាសាកល សម្រាប់ស្តារចំនួនសត្វខ្លាធំឡើងវិញ។

**កញ្ញា ឡុង សាពណ៌** រៀបរាប់ជាចុងក្រោយថា៖ «ការរស់រានរបស់សត្វព្រៃត្រូវទទួលបានការពារដូចមនុស្សដែរ។ យើងដែលជាយុវជនជំនាន់ក្រោយត្រូវតែពួតដៃគ្នា ធ្វើជាសំឡេងរបស់សត្វព្រៃមុនពេលពួកវាផុតពូជពីផែនដីយើង។ ខ្ញុំសង្ឃឹមថាសត្វខ្លាធំនឹងត្រលប់មកកម្ពុជាវិញបាន ហើយពេលនោះខ្ញុំនឹងប្រាប់កូនៗរបស់ខ្ញុំដោយមោទនថា ម្តាយរបស់ពួកគេបានចូលរួមជាចំនែកតូចមួយនៃការមានវត្តមានឡើងវិញនៃសត្វខ្លាធំដ៏មានសារៈសំខាន់ជាសាកលនេះ។»

សេចក្តីប្រកាសនៃកិច្ចប្រជុំកំពូលយុវជននៅឆ្នាំនេះ ជាសញ្ញាណបង្ហាញថាអ្នកដឹកនាំវ័យក្មេងរួមគ្នាអំពាវនាវទៅដល់រដ្ឋាភិបាល រួមនឹងអ្នកធុរកិច្ចនៅក្នុងប្រទេសដែលជាទីជម្រកសត្វខ្លាធំ ដើម្បីធ្វើសកម្មភាពបន្ទាន់រួមគ្នាក្នុងគោលបំណងធានាអនាគតសម្រាប់សត្វខ្លាធំ។ សេចក្តីប្រកាសនេះកើតឡើងមុនពេលការចរចារជាអន្តរជាតិដ៏សំខាន់មួយ ដែលធ្វើឡើងនៅឆ្នាំនេះដើម្បីកំណត់កម្មវិធីស្តារសត្វខ្លាធំសាកល សម្រាប់១២ឆ្នាំបន្ទាប់ទៀត ពោលគឺឆ្នាំ ២០២២- ២០៣៤។

— ចប់—

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

រ៉ាវី សុភារ័ត្ន | WWF-Cambodia | Sophearoth.ravy@wwf.org.kh | Tel: 070409276

Jenny Roberts | WWF | jroberts@wwf-tigers.org

តំណរភ្ជាប់ដើម្បីចុះឈ្មោះចូលរួមកិច្ចប្រជុំកំពូលស្តីអំពីសត្វខ្លាធំ **here**.

តំណរភ្ជាប់សម្រាប់កម្រងរូបភាពរបស់សត្វខ្លាធំ **here**.

## អំពីអង្គការWWF

អង្គការWWF គឺជាស្ថាប័នអភិរក្សឯករាជ្យមួយ ដែលមានអ្នកគាំទ្រជា ៣០លាននាក់ ជាមួយនឹងបណ្តាញអន្តរជាតិនៅតាមបណ្តាប្រទេសជាង១០០។ បេសកកម្មរបស់អង្គការWWFគឺដើម្បីបញ្ឈប់ការខូចខាតនៃបរិស្ថានធម្មជាតិរបស់ភពផែនដី និងដើម្បីកសាងអនាគតដែលមនុស្សរស់នៅដោយសុខដុមជាមួយធម្មជាតិ តាមរយៈការអភិរក្សជីវចម្រុះរបស់ពិភពលោក ធានាឲ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងលើកកម្ពស់ការកាត់បន្ថយការបំពុលនិងការប្រើប្រាស់ខ្ជះខ្ជាយ។ ចុចចូលគេហទំព័ររបស់អង្គការ WWFដើម្បីទទួលបានព័ត៌មានថ្មី និងធនធានផ្សេងៗទៀត។

## អំពីកម្មវិធី គំនិតផ្តួចផ្តើមក្នុងការស្តារសត្វខ្លាធំសាកល

ជាសម្ព័ន្ធភាពសកលនៃរដ្ឋាភិបាល ស្ថាប័នអន្តរជាតិ ស្ថាប័នសង្គមស៊ីវិល ក្រុមអ្នកអភិរក្ស និងអ្នកវិទ្យាសាស្ត្រ និងវិស័យឯកជន ជាមួយគោលដៅរួមមួយ គឺការជួយសង្គ្រោះសត្វខ្លាធំពីការផុតពូជ។ កម្មវិធីនេះ ចង់លើកទឹកចិត្តឲ្យបណ្តាប្រទេសដែលជាទីជម្រកសត្វខ្លាធំ ស្វែងរកដំណោះស្រាយកត្តាគំរាមគំហែងទាំងនៅក្នុងប្រទេសនិងឆ្លងដែន និងធ្វើយ៉ាងណ្តោះទៅរកការបង្កើននិរន្តរភាពហិរញ្ញវត្ថុតាមរយៈការធ្វើសមាហរណកម្មនៃគោលបំណងអភិរក្សទៅក្នុងការអភិវឌ្ឍ។

## ហេតុអ្វីបានជាខ្លាធំមានសារៈសំខាន់?

សត្វខ្លាធំ ជាប្រភេទមំសាសី ស្ថិតនៅក្នុងអម្បូរខ្លាដែលមានមាឌធំជាងគេក្នុងពិភពលោក ហើយវាមួយមានតួនាទីយ៉ាងសំខាន់ ក្នុងប្រព័ន្ធអេកូឡូស៊ីទាំងសម្រាប់ការអាស្រ័យរបស់សត្វព្រៃដទៃ និងមនុស្សផងដែរ។ សត្វខ្លាធំ គឺជាប្រភេទសត្វព្រៃតំណាងឲ្យតំបន់ការពារ ដែលត្រូវការដែនដីធំ និងមានភាពចម្រុះក្នុងការរស់នៅ ហើយដោយមិនមានការរំខានពីមនុស្ស។ ការស្តារសត្វខ្លាធំដែលជាប្រភេទសត្វនិមិត្តរូប និងជាសូចនាករកំណត់នូវគំរូមួយនៃរបៀបដែលយើងនឹងពិចារណាពីអាទិភាពក្នុងការពង្រឹងសុខភាពរបស់ធម្មជាតិក្នុងការអភិវឌ្ឍន៍សកលលោក និងក្នុងបរិបទនៃការផ្លាស់ប្តូរអាកាសធាតុនាពេលខាងមុខ។ សម្រាប់ព័ត៌មានបន្ថែម៖ tigers.panda.org